

បងឆ្មានិងបងឆ្កែ ៖

បងឆ្មាមានពណ៌លឿង

Elke and René Leisink



នេះគឺបងឆ្កែ។




បងឆ្កែកំពុងអង្គុយក្នុងផ្ទះ។ មាននរណាម្នាក់មកគោះទ្វារ។



បងឆ្កែបើកទ្វារ។ បងឆ្កែឃើញនរណាម្នាក់ពណ៌លឿង!



បងឆ្កែសួរ៖ "នរណាគេហ្នឹង?" ម្នាក់នោះគឺបងឆ្មា។

បងឆ្មាមានមានពណ៌លឿង។



ក្បាលបងឆ្មាមានពណ៌លឿង។ រោមបងឆ្មាមានពណ៌លឿង។



ដ់បែងឆ្មាមានពណ៌លឿង។ ហាតដ់បែងឆ្មាមានពណ៌លឿង។



មាត់បងឆ្មាមានពណ៏លឿង។ ច្រមុះបងឆ្មាមានពណ៌លឿង។
ត្រចៀកបងឆ្មាមានពណ៌លឿង។ ភ្នែកបងឆ្មាមានពណ៌លឿង។



បងឆ្កែសួរ៖ "ហេតុអ្វីបានជាឯងមានពណ៌លឿងបែបនេះ?" បងឆ្មាតប៖ "ខ្ញុំមិនដឹងទេ។"




បងឆ្កែសួរ៖ " មុននេះឯងនៅឯណា?" បងឆ្មាតប៖ " មុននេះខ្ញុំនៅសាលារៀន"។




បងឆ្កែសួរ៖ "នៅសាលារៀនណា?" បងឆ្មាតប៖"
ខ្ញុំនៅសាលារៀនក្នុងភូមិ។"



បងឆ្កែសួរ៖ "ឯងនៅសាលារៀនពេលណា?" បងឆ្មាតប៖

"ខ្ញុំនៅសាលារៀនព្រឹកមិញ។"



បងឆ្កែសួរ៖ "តើឯងធ្វើអ្វីនៅសាលារៀន?" បងឆ្មាតប៖

"ខ្ញុំគេងនៅទីនោះ។"




បងឆ្កែលាន់មាត់សួរ៖ "ឯងគេងនៅសាលារៀនមែនទេ? !
ហើយឯងគេងនៅកន្លែងណា?" បងឆ្មាតប៖
"ខ្ញុំគេងនៅក្រោយសាលារៀន។"




បងឆ្កែគិតមួយសន្ទុះ ហើយក៏សរសេរលើក្រដាស៖ នរណា= បងឆ្មា
ឯណា= ខាងក្រោយសាលារៀន សាលារៀនណា= សាលារៀនក្នុងភូមិ
ពេលណា= ពេលព្រឹក ធ្វើអ្វី= គេង ហេតុអ្វី= ?



បន្ទាប់មកទៀតឆ្មានិយាយថា៖"
ខ្ញុំមិនមែននៅសាលារៀនតែម្នាក់ឯងនោះទេ គឺមានម្នាក់ទៀត។"



បងឆ្កែសួរ៖"តើម្នាក់ទៀតនៅសាលារៀននោះជានរណា?" បងឆ្មាតប៖"
បងដំរីក៏នៅសាលារៀនដែរ។"



បងឆ្កែសួរ៖"តើបងដំរីធ្វើអ្វី?" បងឆ្មាតប៖"បងដំរីកំពុងលាបពណ៌។"



បងឆ្កែសួរ៖ "តើបងដ៊ីរលាបពណ៌ទៅលើអ្វី?" បងឆ្មាតប៖

"បងដ៊ីរលាបពណ៌សាលារៀន។"



បងឆ្កែសួរ៖ "តើបងដឹរលាបពណ៌សាលារៀនដោយរបៀបណា?"

បងឆ្មាតប៖ "គាត់លាបពណ៌សាលារៀនជាមួយជក់ដ៏ធំមួយ។"




បងឆ្មាស្ងាត់មាត់។ បងឆ្មាគិតហើយនិយាយថា៖ "ឥឡូវខ្ញុំដឹងហើយ ថាហេតុអ្វីបានជាខ្ញុំមានពណ៌លឿង!"



បងឆ្មានិងបងឆ្កែដើរទៅសាលារៀនទាំងពីរនាក់។

បងដំរីកំពុងតែលាបពណ៌សាលារៀន។

បងដំរីកំពុងលាបសាលារៀនពណ៌លឿង។



បងដឺរីលាបពណ៌លើអ្វីៗទាំងអស់។ បងដឺរីមិនត្រឹមតែលាបពណ៌សាលារៀនទេ ថែមទាំងលាបពណ៌បងឆ្មាទៀត។



លាហើយ បងឆ្មាពណ៌លឿង។ លាហើយ បងឆ្កែ។ លាហើយ បងដំរី។

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org To read more books like this and get further information, visit letsreadasia.org .

Original Story Cat & Dog: Cat Is Yellow, author: Elke and René Leisink . illustrator: René & Elke Leisink. Published by Biblionef, http://cat-and-dog.org/ © Biblionef. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/